ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
東埔寨郵政銀行 CAMBODIA POST BANK PLC.

# ព្រឹត្តិបត្រព័ត៌មាន

ខែកក្កដា ឆ្នាំ២០២៣
លេខ០១

## សេដ្ឋកិច្ចពិភពលោក

សេដ្ឋកិច្ចពិភពលោកកំពុងប្រឈមមុខនឹងបញ្ហាយ៉ាងធ្ងន់ធ្ងរ ស្របពេលកំណើនសេដ្ឋកិច្ចត្រូវបានគេរំពឹងថានឹងថយចុះ ហើយអតិផរណា និងភាពមិនប្រាកដប្រជាបានកើនឡើងខ្ពស់ ដោយសារជំងឺកូវីដ១៩ សង្គ្រាមក្នុងប្រទេសអ៊ុយក្រែន ការរឹតបន្តឹងរូបិយវត្ថុ ការប្រែប្រួលអាកាសធាតុ បញ្ហាហិរញ្ញវត្ថុនៅសហរដ្ឋអាមេរិក និងអឺរ៉ុប និងការផ្លាស់ប្តូរលក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ អតិផរណាដ៏ខ្ពស់នេះទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍បានជំរុញឱ្យមានការដំឡើងអត្រាការប្រាក់ខ្ពស់បំផុតដែលមិនធ្លាប់មានក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ និងបានបណ្តាលឱ្យលក្ខខណ្ឌហិរញ្ញវត្ថុកាន់តែត្រូវបានរឹតបន្តឹង និងធ្វើឱ្យហានិភ័យបំណុលកាន់តែធ្ងន់ធ្ងរ។

ទោះជាកំណើនសេដ្ឋកិច្ចសកលត្រូវបានធ្លាក់ចុះ ក៏សេដ្ឋកិច្ចនៅឆ្នាំ២០២៣ មិនមានភាពធ្ងន់ធ្ងរខ្លាំងដល់កម្រិតដែលត្រូវបានគេព្យាករទុកនោះឡើយ ដោយសារការចំណាយរបស់ប្រជាជនសហរដ្ឋអាមេរិក និងសហភាពអ៊ឺរ៉ុបមានការកើនឡើង រួមទាំងការងើបឡើងវិញនៃសេដ្ឋកិច្ចនៅក្នុងប្រទេសចិន និងកំណើនសេដ្ឋកិច្ចប្រទេសឥណ្ឌា។ កំណើនសេដ្ឋកិច្ចសកលត្រូវបានព្យាករថានឹងធ្លាក់ចុះពី ៣,១% នៅក្នុងឆ្នាំ២០២២ ទៅ ២,៣% នៅក្នុងឆ្នាំ២០២៣ (ការព្យាករក្នុងខែមករា គឺ១,៩%)។ សេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករណ៍ថានឹងកើនឡើង ២,៥% នៅឆ្នាំ២០២៤ ជាមួយនឹងសម្ពាធអតិផរណាថយចុះពី ៧,៥%នៅក្នុងឆ្នាំ២០២២ ដល់ ៥,២% នៅក្នុងឆ្នាំ២០២៣ ភាគច្រើនដោយសារតម្លៃអាហារ និងថាមពលបានធ្លាក់ចុះទាប និងតម្រូវការសាកលមានការថយចុះ។

បញ្ហាប្រឈមរបស់សេដ្ឋកិច្ចរយៈពេលខ្លី និងមធ្យមបណ្តាលមកពីការផ្លាស់ប្តូរសេដ្ឋកិច្ចពិភពលោកទៅតាមស្ថានភាពនានាក្នុងឆ្នាំ២០២០-២០២២ និងអស្ថិរភាពនៃវិស័យហិរញ្ញវត្ថុនាពេលថ្មីៗនេះ។ ក្តីបារម្ភអំពីវិបត្តិសេដ្ឋកិច្ចបានកើនឡើង ខណៈពេលដែលការព្រួយបារម្ភអំពីអតិផរណាខ្ពស់នៅតែបន្តកើតមាន។ ភាពច្របូកច្របល់នៃប្រព័ន្ធធនាគារនាពេលថ្មីៗនេះនឹងបណ្តាលឱ្យមានការរឹតបន្តឹងលក្ខខណ្ឌហិរញ្ញវត្ថុសកលយ៉ាងខ្លាំង ដែលបានធ្វើឱ្យអាជីវកម្ម និងអ្នកប្រើប្រាស់ទូទៅមិនមានទំនុកចិត្តដូចមុន។ ហានិភ័យមួយទៀតនោះគឺជាការដំឡើងនូវអត្រាការប្រាក់របស់ធនាគារកណ្តាល ស្របពេលដែលបំណុល

Figure 1

**Growth of economic output in the world, developed and developing economies**




Source: UN DESA, based on estimates and forecasts produced with the World Economic Forecasting Model.
Note: **e** = estimates, **f** = forecasts.

ឯកជន និងសាធារណៈមានកម្រិតខ្ពស់ មិនធ្លាប់មាន។ ថ្លៃដើមកម្ចីខ្ពស់ និងកំណើនទាបអាចបណ្តាលឱ្យមានវិបត្តិបំណុលជាប្រព័ន្ធនៅក្នុងទីផ្សារដែលកំពុងរីកចម្រើន និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍។ លើសពីនេះទៅទៀត អតិផរណាអាចបន្តក្នុងរយៈពេលយូរ ដែលជំរុញឱ្យមានការរឹតបន្តឹងរូបិយវត្ថុខ្លាំងជាងការរំពឹងទុកនាពេលបច្ចុប្បន្ន។ ហានិភ័យផ្សេងទៀតគឺបណ្តាលមកពីការស្តារសេដ្ឋកិច្ចឡើងវិញរបស់ប្រទេសចិនក្រោយ កូវីដ១៩ សង្គ្រាមនៅអ៊ុយក្រែន និងការបែងចែកតំបន់សេដ្ឋកិច្ច ដែលជាឧបសគ្គ ដល់ការសហការគ្នាក្នុងការដោះស្រាយបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចជារួម។ ជាមួយនឹងកម្រិតបំណុល អតិផរណា និងការប្រែប្រួលនូវទីផ្សារហិរញ្ញវត្ថុ អ្នកបង្កើតគោលនយោបាយ ជាពិសេសនៅក្នុងប្រទេសដែលមានចំណូលទាប មានជម្រើសតិចតួចបំផុតក្នុងការដោះស្រាយវិបត្តិថ្មីៗ។

# សេដ្ឋកិច្ចអាស៊ាន ឆ្នាំ២០២៣

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ឬហៅកាត់ថា «អាស៊ាន» គឺជាតំបន់មួយ ដែលមានការរីកចម្រើនលឿនបំផុតនៅលើពិភពលោកក្នុងឆ្នាំ២០២២។ មួយផ្នែកនៃការរីកចម្រើននេះ គឺដោយសារការឆ្លើយតបទាន់ពេលវេលា និងសមស្រប តាមរយៈគោលនយោបាយរូបិយវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច ដំណើរការនាំចេញល្អ និងតម្រូវការក្នុងស្រុកដ៏រឹងមាំនៅក្នុងប្រទេសមួយចំនួន។ ស្ថិរភាពវិស័យធនាគារក្នុងសេដ្ឋកិច្ចអាស៊ី នៅតែរឹងមាំ ដែលអាចបញ្ជាក់បានតាមរយៈសមាមាត្រខ្ពស់នៃដើមទុនគ្រប់គ្រាន់ និងបទប្បញ្ញត្តិកាន់តែប្រសើរ។ វិស័យធនាគារត្រូវតែត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នក្នុងបរិយាកាសអតិផរណាដែលមានការប្រាក់ខ្ពស់នាពេលបច្ចុប្បន្ន។ ទោះបីជាវិស័យធនាគារពិភពលោកបានជួបប្រទះភាពចលាចលក្នុងខែមីនា ឆ្នាំ២០២៣ ជាមួយនឹងការបរាជ័យរបស់ធនាគារ Silicon Valley (SVB) និង Signature Bank ក៏ដោយ វិស័យធនាគារនៅក្នុងតំបន់អាស៊ីនៅតែមានភាពរឹងមាំដដែល។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងឆ្នាំ២០២៣ យើងប្រឈមនឹងការផ្លាស់ប្តូរជាបន្តបន្ទាប់នៃសម្ពាធសេដ្ឋកិច្ចដែលនឹងជះឥទ្ធិពលយ៉ាងខ្លាំងដល់កំណើនសេដ្ឋកិច្ចពិភពលោក។ នៅក្នុងឆ្នាំ២០២៣ តំបន់អាស៊ី និងប៉ាស៊ីហ្វិកនឹងក្លាយជាតំបន់ដែលមានកំណើនសេដ្ឋកិច្ចខ្លាំងបំផុត ក្នុងចំណោមតំបន់សំខាន់ៗនៅពិភពលោក ដែលកំណើននេះភាគច្រើនកើតចេញពីកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិន និងឥណ្ឌា។

ទីផ្សារសេដ្ឋកិច្ចដែលកំពុងរីកចម្រើនខ្លាំងទាំងពីរនេះ ត្រូវបានគេរំពឹងថានឹងរួមចំណែក៥០%នៃកំណើនសេដ្ឋកិច្ចពិភពលោកនៅក្នុងឆ្នាំនេះ។ ទោះបីជាតម្រូវការខាងក្រៅមានការថយចុះ ដូចជាការធ្លាក់ចុះនៃតម្រូវការបច្ចេកវិទ្យារហូតដល់ចុងឆ្នាំ២០២២ និងការរឹតបន្តឹងរូបិយវត្ថុក៏ដោយ ក៏តម្រូវការក្នុងស្រុករហូតមកដល់ពេលនេះនៅតែមានភាពរឹងមាំ ជាមួយនឹងការបើកដំណើរការឡើងវិញរបស់ប្រទេសចិន ដែលបានផ្តល់នូវកម្លាំងរុញច្រានថ្មី។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ថ្មីៗនេះបានកែប្រែការព្យាករណ៍កំណើនសេដ្ឋកិច្ចរបស់តំបន់អាស៊ាននៅក្នុងឆ្នាំ២០២៣ មកត្រឹម៤,៧% ដោយសារតម្រូវការសកលធ្លាក់ចុះ។ កំណើនសេដ្ឋកិច្ចរបស់អាស៊ានត្រូវបានគេរំពឹងថានឹងធ្លាក់ចុះពី៥,៧% នៅឆ្នាំ២០២២ មក ៤,៦% ក្នុងឆ្នាំ២០២៣ ដោយសារតម្រូវការក្នុងស្រុកមានកម្រិតតិចតួច (ម៉ាឡេស៊ី និងថៃ) ការរឹតបន្តឹងរូបិយវត្ថុ (ហ្វីលីពីន) ការបន្ធូរបន្ថយតម្លៃទំនិញ (ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី) និងតម្រូវការតិចពីសហរដ្ឋអាមេរិក និងអឺរ៉ុប។




ហានិភ័យចំពោះសេដ្ឋកិច្ចនៅបន្តកើតមានដោយសារភាពមិនប្រាកដប្រជាបន្តជះឥទ្ធិពលដល់តំបន់អាស៊ី ស្របពេលអតិផរណាសកល និងក្នុងតំបន់អាចនឹងមានកម្រិតខ្ពស់ជាងការរំពឹងទុក។ ការរឹតបន្តឹងនៅក្នុងលក្ខខណ្ឌហិរញ្ញវត្ថុដោយសារតែការដំឡើងអត្រាការប្រាក់ដោយធនាគារកណ្តាល លើសពីអ្វីដែលទីផ្សាររំពឹងទុកនាពេលបច្ចុប្បន្នអាចបង្កឱ្យមានហានិភ័យស្ថិរភាពហិរញ្ញវត្ថុ។ ហានិភ័យទាំងនេះកាន់តែធំនៅក្នុងទីផ្សារដែលមានអតិផរណាខ្ពស់។ ក្នុងរយៈពេលមធ្យម ការបែកខ្ញែកនៃភូមិសាស្ត្រសេដ្ឋកិច្ច និងការធ្លាក់ចុះនៃសេដ្ឋកិច្ចក្នុងប្រទេសចិន អាចរារាំងដល់កំណើនសេដ្ឋកិច្ចអាស៊ី។ ហានិភ័យផ្សេងទៀត កើតចេញពី ១. សម្ពាធក្នុងវិស័យធនាគារ និងការថយចុះសកម្មភាពសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិក និងអឺរ៉ុប ដែលអាចធ្វើឱ្យតម្រូវការខាងក្រៅនៅអាស៊ីធ្លាក់ចុះ ២. ភាពច្របូកច្របល់នៃវិស័យអចលនវត្ថុក្នុងប្រទេសចិនកាន់ធ្ងន់ធ្ងរ ដែលអាចបង្កគ្រោះថ្នាក់ដល់ការងើបឡើងវិញនៃសេដ្ឋកិច្ចប្រទេសចិន និងអាចប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចក្នុងតំបន់ ៣. បំណុលច្រើននៅក្នុងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ដែលអាចនាំឱ្យមានបញ្ហាបំណុលដល់ប្រទេស។ សម្ពាធអតិផរណាបានបណ្តាលឱ្យមានបញ្ហាសន្តិសុខស្បៀង និងបង្កើនភាពប្រែប្រួលនៃលំហូរមូលធន។ ជាមួយនឹងការប្រែប្រួលអត្រាការប្រាក់ ការរាំងស្ទះផ្នែកផ្គត់ផ្គង់ក្នុងអំឡុងពេលជំងឺកូវីដ១៩ និងបញ្ហាថ្មីៗដែលបង្កឡើងដោយភាពមិនប្រាកដប្រជាជាសកល ការពង្រឹងវិស័យទេសចរណ៍ គឺជាសកម្មភាពអាទិភាពក្នុងការជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ានក្នុងឆ្នាំ ២០២៣-២០២៤។ តម្រូវការក្នុងស្រុកអាចមានកម្រិតខ្ពស់ជាងការរំពឹងទុក ទោះបីជាវាអាចប៉ះពាល់ដល់អតិផរណាក៏ដោយ។



# សេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០២៣



**Figure 1** Economic recovery solidified
Contribution to real GDP growth (percent)

ផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាដំបូងត្រូវបានជំរុញដោយវិស័យឧស្សាហកម្ម ដែលផ្តោតលើការនាំចេញ។ បច្ចុប្បន្ន សេដ្ឋកិច្ចកម្ពុជាកំពុងប្រសើរឡើងវិញ ដោយសារការស្ទុះងើបឡើងវិញយ៉ាងខ្លាំងនៃវិស័យសេវាកម្ម (ពិសេសពាណិជ្ជកម្ម ទេសចរណ៍ និងបដិសណ្ឋារកិច្ច) តម្រូវការអ្នកប្រើប្រាស់មានការកើនឡើង និងការត្រឡប់មកវិញនៃភ្ញៀវទេសចរបរទេស។ នៅក្នុងខែមករា ដល់ខែមេសា ឆ្នាំ២០២៣ ការនាំចូលមានតម្លៃសរុប ៧,៩ពាន់លានដុល្លារអាមេរិក ខណៈការនាំចេញមានតម្លៃសរុប៧,២ពាន់លានដុល្លារអាមេរិក។ ការនាំចេញត្រូវបានគេព្យាករថានឹងកើនឡើង ១៨,៥% ក្នុងឆ្នាំ២០២៣ ខណៈការនាំចូលត្រូវបានគេរំពឹងថានឹងធ្លាក់ចុះ១០,៣% ក្នុងឆ្នាំ២០២៣។ ទុនបម្រុងសម្រាប់ការប្តូរប្រាក់បរទេស មានប្រមាណ១៧,៧ពាន់លានដុល្លារអាមេរិក ក្នុងខែកុម្ភៈ ឆ្នាំ២០២៣ (ប្រហែលនឹងតម្លៃនៃការនាំចូលរយៈពេល ៧ខែ) ខណៈធនាគារពិភពលោកព្យាករថាទុនបម្រុងនេះមានចំនួន១៥,៨ពាន់លានដុល្លារក្នុងឆ្នាំ ២០២៣។ ជាមួយនឹងតម្លៃថាមពលសកល អតិផរណាត្រូវបានព្យាករថា ជាមធ្យមគឺ៣.0% និងអាចកើនឡើងដល់ ៤.0% នៅឆ្នាំ២០២៤។

អតិផរណាប្រចាំឆ្នាំស្ថិតនៅ ៣.0% បើគិតត្រឹមចុងខែមករាឆ្នាំ២០២៣ ដែលនេះបានប៉ះពាល់ដល់តម្លៃម្ហូបអាហារ ការដឹកជញ្ជូន និងសម្ភារៈលំនៅដ្ឋាន។ អត្រាប្តូរប្រាក់ នៅថេរ ប្រហែល ៤,១០០រៀល ក្នុង១ដុល្លារអាមេរិច។ អត្រាប្តូរប្រាក់នេះនឹងបន្តមានស្ថិរភាពក្នុងឆ្នាំ២០២៤ ដោយសារវិស័យទេសចរណ៍ ដែលជួយជំរុញសេដ្ឋកិច្ច។

ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចកម្ពុជាអាចប្រឈមនឹងហានិភ័យមួយចំនួន ដូចជាការធ្លាក់ចុះនៃតម្រូវការខាងក្រៅដែលអាចបន្តធ្វើឱ្យផលិតកម្មសម្រាប់ការនាំចេញរបស់កម្ពុជាធ្លាក់ចុះ ដែលកាត់បន្ថយប្រហែល៤០%នៃការងារសរុបនៅក្នុងវិស័យឧស្សាហកម្ម។ ការបន្តរឹតបន្តឹងហិរញ្ញវត្ថុសកលអាចជះឥទ្ធិពលដល់វិស័យមួយចំនួនរួមមានវិស័យសំណង់ជាដើម។ ការឡើងតម្លៃប្រេងជាថ្មី អាចធ្វើឲ្យមានអតិផរណា និងបង្អាក់ការប្រើប្រាស់នៅក្នុងស្រុក។ ឥណទានក្នុងស្រុកក្នុងវិស័យសំណង់នៅតែជាហានិភ័យ ចំពោះស្ថិរភាពហិរញ្ញវត្ថុ។ ផ្ទុយទៅវិញ កំណើនសេដ្ឋកិច្ចសកល ដែលខ្លាំងជាងការរំពឹងទុក អាចកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃតម្រូវការខាងក្រៅដែលបានធ្លាក់ចុះ។ ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចប្រទេសចិនអាចជំរុញវិស័យទេសចរណ៍ ការនាំចេញ និងការវិនិយោគផ្ទាល់ពីបរទេសកាន់តែខ្លាំង ដែលអាចជួយស្តារការធ្លាក់ចុះ នៃកំណើនសេដ្ឋកិច្ចជាមុន។ លើសពីនេះទៅទៀត កំណើនសេដ្ឋកិច្ចជាមុនមានកំណើនយឺតជាងការរំពឹងទុកផងដែរ ដែលអាចបណ្តាលឱ្យមានការធ្លាក់ចុះនៃការនាំចេញ។







សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ជូនចំពោះ**
**លោក-លោកស្រីនាយក**
**ធនាគារប្រៃសណីយ៍កម្ពុជា ក.អ**
CAMBODIA POST BANK PLC.
**លេខអត្តសញ្ញាណកម្មសារពើពន្ធ** L001-100192777

ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរដោយស្មោះអស់ពីដួងចិត្តជូនចំពោះ លោក-លោកស្រីនាយកធនាគារ ដែលបានចូលរួមចំណែកក្នុងការបំពេញកាតព្វកិច្ចបង់ពន្ធដារផ្ទៃក្នុងជូនរដ្ឋ និងជាសហគ្រាសជាប់ចំណាត់ថ្នាក់លេខ ២៨ ក្នុងចំណោមសហគ្រាសដែលបានបង់ពន្ធច្រើនជាងគេ និងទទួលបានអនុលោមភាពសារពើពន្ធប្រភេទមាស ក្នុងឆ្នាំ២០២២។

ការបំពេញកាតព្វកិច្ចបង់ពន្ធរបស់សហគ្រាសលោក-លោកស្រី គឺជាការចូលរួមចំណែកដែលមិនអាចខ្វះបានពីវិស័យឯកជនដែលជាដៃគូដ៏សំខាន់របស់រដ្ឋ និងជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍនិងរីកលូតលាស់នៃសេដ្ឋកិច្ច និងសង្គមជាតិកម្ពុជា។

សូមជូនពរលោក-លោកស្រីនាយក ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់និងបុគ្គលិកទាំងអស់ទទួលបានជោគជ័យរាល់កិច្ចអាជីវកម្ម និងសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃពុធ ១០ កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣

**ហ៊ុន សែន**

លិខិតសរសើរ ពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដោយទទួលស្គាល់ថា
ជាសហគ្រាសបង់ពន្ធច្រើនជាងគេលំដាប់ទី ២៨ នៅកម្ពុជាប្រចាំឆ្នាំ២០២២


ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

TCG23010656322

Phnom Penh, 10th, Jan 2023

អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

វិញ្ញាបនបត្រ
អនុលោមភាពសារពើពន្ធ

ឈ្មោះក្រុមហ៊ុន ៖ ធនាគារប្រៃសណីយ៍កម្ពុជា ក.អ

ទទួលបានកម្រិតអនុលោមភាពសារពើពន្ធប្រភេទ ៖ មាស

CERTIFICATE OF TAX COMPLIANCE
(Prakas No 1536 MEF/PK dated 23rd December 2016)

GENERAL DEPARTMENT OF TAXATION certifies that :

Company's name : CAMBODIA POST BANK PLC.

Tax Identification Number (TIN) : L001-100192777

Under : Department of large Taxpayers    Date of Information Update : 26 Jan 2017

Business activity(ies) : Banking service

Tax Compliance Type awarded : GOLD

Validity period of **2 years** for the tax year of **2022** and **2023**.

Minister Attached to the Prime Minister
Delegate of the Royal Government
in charge as Director General of General Department of Taxation

គង់ វិបុល

វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ “មាស” ពីអគ្គនាយកដ្ឋានពន្ធដារ
ដែលមានសុពលភាពរយៈពេល ២ឆ្នាំ ចាប់ពីឆ្នាំ ២០២២ ដល់ឆ្នាំ ២០២៣




ពានរង្វាន់ ឧត្តមភាពពាណិជ្ជកម្ម ជាធនាគារ ដែលទទួលបានទំនុកចិត្តខ្ពស់បំផុត
ប្រចាំឆ្នាំ២០២២ នៅទីក្រុងHouston នៃរដ្ឋ Texas សហរដ្ឋអាមេរិក
នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០២៣

# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ឧបត្ថម្ភតុ និងកៅអីជូនអង្គការអាហ្វេស៊ីបកម្ពុជា

នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អបានឧបត្ថម្ភ តុកុំព្យូទ័រចំនួន១០ តុបាយចំនួន៥ កៅអីចំនួន៥០ និងទឹកសុទ្ធ ៥០យួរ ជូនដល់អង្គការអាហ្វេស៊ីបកម្ពុជា ដើម្បីប្រើប្រាស់ប្រចាំថ្ងៃ។

ធនាគារក៏សូមអំពាវនាវ និងលើកទឹកចិត្តបងប្អូនប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ចូលរួមបរិច្ចាគជូនអង្គការអាហ្វេស៊ីបកម្ពុជា ដែលកំពុងតែត្រូវការជំនួយបន្ថែម ដើម្បីរួមចំណែកជាមួយអង្គការ ក្នុងការជួយយុវនារី និងកុមារីរងគ្រោះ និងងាយរងគ្រោះកម្ពុជា ឱ្យពួកគាត់ទទួលបានឱកាសក្នុងការក្រោកឈរឡើងវិញ និងអភិវឌ្ឍខ្លួន ឱ្យក្លាយជាធនធានរបស់សង្គមនាថ្ងៃខាងមុខ។

**គណនីសម្រាប់បរិច្ចាគៈ**

| AFESIP CAMBODIA | AFESIP CAMBODIA |
|---|---|
| 061 601 601 \|KHR | 061 601 601 \|USD |



# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ចែករំលែកក្តីស្រឡាញ់ជូនបុគ្គលិកស្រ្តី

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ចែករំលែកក្តីស្រឡាញ់ជូនបុគ្គលិកជាស្រ្តីគ្រប់រូប នាឱកាសអបអរសាទរខួបទី១១២ នៃទិវាអន្តរជាតិនារី។ ធនាគារ តែងតែផ្តល់គុណតម្លៃ និងលើកកម្ពស់សមភាពយេនឌ័រ។






# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ គាំទ្រយុទ្ធនាការ «ការយល់ដឹងអំពីហិរញ្ញវត្ថុ»




ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ តែងតែគាំទ្រយុទ្ធនាការ «ការយល់ដឹងអំពីហិរញ្ញវត្ថុ» ដែលជាផ្នែកមួយនៃការចូលរួមក្នុងកិច្ចការសង្គមរបស់ធនាគារ។

ជាថ្មីម្តងទៀត ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានក្លាយជាអ្នកឧបត្ថម្ភធំ Diamond Sponsor ក្នុងវគ្គបណ្តុះបណ្តាល “អ្នកសារព័ត៌មាន លើមូលដ្ឋានគ្រឹះនៃវិស័យហិរញ្ញវត្ថុនៅកម្ពុជា” ដែលរៀបចំឡើងដោយសមាគមធនាគារនៅកម្ពុជា(ABC) សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) និងសមាគមធានារ៉ាប់រងកម្ពុជា (IAC) ដោយសហការជាមួយ ក្លឹបអ្នកកាសែតកម្ពុជា (CCJ) ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុជាមូលដ្ឋានដល់អ្នកសារព័ត៌មាន ក្នុងការសរសេរអត្ថបទព័ត៌មាន អំពីវិស័យធនាគារ ហិរញ្ញវត្ថុ និងធានារ៉ាប់រង ឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ។

កម្មវិធីបើកវគ្គបណ្តុះបណ្តាលនេះ បានរៀបចំឡើងនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា។

# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បរិច្ចាគថវិកា ៤០លានរៀល ជូនកាកបាទក្រហមកម្ពុជា

ធនាគារប្រៃសណីយ៍កម្ពុជា ក.អ បានបរិច្ចាគថវិកា ៤០លានរៀល ជូនកាកបាទក្រហមកម្ពុជា ក្នុងពិធីអបអរខួបទី ១៦០ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៣។

ការបរិច្ចាគនេះ គឺជាសក្ខីភាពមួយទៀតនៃការប្តេជ្ញាចិត្តរបស់ធនាគារ ក្នុងការចូលរួមនៅក្នុងសកម្មភាពរបស់សង្គម។



# ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ រៀបចំកម្មវិធី «បរិស្ថានស្អាត សុខភាពល្អ»



ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានរៀបចំកម្មវិធី «បរិស្ថានស្អាត សុខភាពល្អ» ដែលចូលរួមដោយលោកនាយក-នាយិកា និងបុគ្គលិកធនាគារ ដោយដើររើសសំរាមសម្អាតបរិស្ថាននៅតាមសួន និងដងផ្លូវសាធារណៈនៅគ្រប់ខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា នៅព្រឹកថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២៣។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងដើម្បីអបអរសាទរទិវាបរិស្ថានជាតិ និង បរិស្ថានពិភពលោក និងដើម្បីរួមចំណែកការពារបរិស្ថានធម្មជាតិ ក៏ដូចជា បណ្ដុះស្មារតី ស្រឡាញ់ ថែរក្សាបរិស្ថាន និងកាត់បន្ថយការបម្រែបម្រួលអាកាសធាតុពិភពលោក ។

សកម្មភាពនេះក៏ជាសារក្រើនរំលឹកដល់សាធារណៈជនឱ្យចេះទុកដាក់សំរាមឱ្យបានត្រឹមត្រូវ និងជៀសវាងការចោលសំរាមពាសវាលពាសកាល ដើម្បីការរស់នៅស្អាត បរិស្ថានស្អាត និងសេចក្ដីថ្លៃថ្នូរផងដែរ។



# ទីតាំងថ្មី៖ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាបឹងទំពុន




ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាបឹងត្របែក បានផ្លាស់ប្ដូរទៅកាន់ទីតាំងថ្មី និងប្ដូរឈ្មោះថា សាខាបឹងទំពុន ចាប់ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ នេះតទៅ ដែលមាន៖

អាសយដ្ឋាន: ផ្លូវលេខ ២៧១ ភូមិក្បាលទំនប់១ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

Google Maps: https://goo.gl/maps/MMjdMswWtdiFXyho9

លេខទូរសព្ទនាយកសាខា: ០៦៩ ៦០០ ០៩២

# កម្មវិធី ព្រឹត្តិការណ៍ដែលធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានចូលរួម៖



ពិព័រណ៍ពាក់កណ្ដាលឆ្នាំ (Mid-Year Mega Sale)
ថ្ងៃទី១៧-១៨ ខែមិថុនា ឆ្នាំ២០២៣
នៅក្នុង The Premier Centre Sen Sok




“ពិព័រណ៍ SEA GAME Top Brand Fair ២០២៣”
ថ្ងៃទី០៥ ដល់ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣
នៅផ្លូវ OCIC ជ្រោយចង្វារ(ក្នុងបរិវេណវិមានអាហារ)



កម្មវិធី “អិនឃូអឹម សង្ក្រាន្ត”
ថ្ងៃទី៣១ ខែមីនា និងថ្ងៃទី១-២ ខែមេសា ឆ្នាំ២០២៣
នៅក្នុងបរិវេណសាកលវិទ្យាល័យ ជាតិគ្រប់គ្រង



កម្មវិធី “ទិវាវប្បធម៌អន្តរជាតិ”
ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៣
សាលាអន្តរជាតិ CIA FIRST International School សាខាច្បារអំពៅ



កម្មវិធី “ទិវារត់ប្រណាំងស្ត្រី ចម្ងាយ១០គ.ម”
ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣
សួនច្បារ វត្តបទុមវត្តី



កម្មវិធី “ទិវាបុណ្យនៃក្តីស្រលាញ់ Valentine’s Day”
ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣
នៅ MC Park សង្កាត់ស្ទឹងមានជ័យ

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វូណនទទួលបានពានរង្វាន់ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

# ដែលរីកចម្រើនលឿនជាងគេក្នុងប្រទេសកម្ពុជា ឆ្នាំ២០២៣




ជាមួយនឹងនិទ្នាការនៃសន្ទុះអាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វូណន ភីអិលស៊ី នៅត្រីមាសទីមួយដើម ឆ្នាំ២០២៣នេះ គ្រឹះស្ថានទទួលបានពានរង្វាន់ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលរីកចម្រើនលឿនជាងគេក្នុងប្រទេសកម្ពុជា ក្នុងកម្មវិធីពានរង្វាន់ធនាគារនិងហិរញ្ញវត្ថុសកលឆ្នាំ២០២៣។ ការទទួលបាននូវពានរង្វាន់នេះ បានឆ្លុះបញ្ចាំងទៅនឹងការរីកចម្រើនរបស់គ្រឹះស្ថាន ចាប់តាំងពីការផ្ទេរភាគទុនិកជាផ្លូវការមកធនាគារ ប្រៃណីយ៍កម្ពុជា ក.អ ពោលគឺមានរយៈពេលជាងប្រាំមួយឆ្នាំមកហើយ។ ក្នុងឆ្នាំ២០១៦ មុនការផ្ទេរភាគទុនិក ទ្រព្យសកម្មរបស់គ្រឹះស្ថានមានទំហំជាង ១២លានដុល្លារអាមេរិក និងមានកំណើនរហូតដល់ ៨២លានដុល្លារអាមេរិក គិតត្រឹមបំណាច់ឆ្នាំ២០២២ នេះ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វូណន ភីអីលស៊ី ជាក្រុមហ៊ុនបុត្រសម្ព័ន្ធ នៃធនាគារ ប្រៃណីយ៍កម្ពុជា ក.អ ហើយមានទីផ្សារគោលដៅផ្តោតទៅអ្នកមានចំណូលទាប ជាពិសេសប្រជាជនកម្ពុជានៅតាមទីជនបទដែលធនាគារពិបាកក្នុងការចាប់យក ក្នុងគោលដៅបំពេញបន្ថែមនូវ ទីផ្សារគោលដៅចម្រុះ (Mass Market) របស់ធនាគារប្រៃណីយ៍កម្ពុជា ក.អ ដែលជាក្រុមហ៊ុនមេរបស់ខ្លួន ក្នុងការលើកកម្ពស់បរិយាបទហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។ ជាមួយនឹងបណ្តាញប្រតិបត្តិការច្រើនជាងគេ ក្នុងចំណោម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ-សន្សំ(៥១សាខា) ហ្វូណនអាចផ្តល់នូវសេវាហិរញ្ញវត្ថុរបស់ខ្លួនទូទាំងប្រទេស ជាពិសេសតំបន់ដែលសេវាហិរញ្ញវត្ថុមិនទាន់មានទូលំទូលាយ។

**FUNAN Microfinance Plc., LOAN BY PROVINCE**



# CPBank

## ស្កែនទូទាត់ QR នៅប្រទេសថៃ
## កាន់តែងាយស្រួលជាមួយ CPBank App

